# រឿង រ៉ាស្សូម៉ុន

### អាគុតាហ្គាវ៉ា រ្យូណុស៊ុគេ

ថ្ងៃមួយ នៅពេលល្ងាច មានបុរសអ្នកបម្រើឋានៈទាបម្នាក់ កំពុងរង់ចាំភ្លៀងរាំង នៅក្រោមទ្វាររ៉ាស្សូម៉ុន[1] ។

នៅក្រោមទ្វារដ៏ធំនោះ គ្មាននរណាម្នាក់ក្រៅពីបុរសនោះទេ គឺមានតែសត្វចង្រិតតូចមួយនៅទំជាប់នឹងសសរធំមូលពណ៌ក្រហមដែលមានរបកថ្នាំបន្តិចបន្តួចតែប៉ុណ្ណោះ។ ទ្វាររ៉ាស្សូម៉ុននោះមានទីតាំងស្ថិតនៅលើវិថី ស៊ូស្សាក់គុអូយ៉ី[2] ដូច្នេះតាមធម្មតានៅក្រោមទ្វារនោះ អាចមានមនុស្សពីរបីនាក់ផ្សេងទៀតជ្រកភ្លៀងបាន ពោលគឺមនុស្សទាំងនោះអាចជា អ៊ីជីមេហ្គាសា[3]ឬក៏ ម៉ុមីអេបុស៊ី[4]។ ប៉ុន្តែតាមពិតគ្មាននរណាក្រៅពីបុរសនោះឡើយ។

នៅប៉ុន្មានឆ្នាំថ្មីៗនេះ ទីក្រុងក្យូតុ[5]មានគ្រោះមហន្តរាយជាច្រើន ដូចជា រញ្ជួយដី ខ្យល់កួច អគ្គិភ័យ ទុរ្ភិក្ស ។ល។ ដែលបញ្ហានេះនាំឱ្យទីក្រុងមានការថយចុះយ៉ាងខ្លាំង។ តាមកំណត់ត្រាចាស់ៗបានសរសេរថា ប្រជាជនបានវាយកម្ទេចពុទ្ធបដិមា និងគ្រឿងសក្ការៈផ្សេងៗ ដាក់គរនៅតាមបណ្តោយផ្លូវ ដោយមានកម្ទេចថ្នាំលាបពណ៌មាស ប្រាក់ នៅជាប់ជាមួយ ហើយដាក់លក់ជាឧស។ ដោយមានការជ្រួលច្របល់នៅក្នុងទីក្រុងដូចនេះ គ្មាននរណាម្នាក់ខ្វល់ខ្វាយនឹងថែរក្សាទ្វាររ៉ាស្សូម៉ុនទេ។ វានាំឱ្យសត្វកញ្ជ្រោង និងស្ការជាច្រើនបានមករស់នៅកន្លែងដ៏ទ្រុឌទ្រោមនេះ ហើយបន្ទាប់មកក៏មានចោរមករស់នៅដែរ។ ចុងបញ្ចប់ វាបានក្លាយទៅជាទម្លាប់មួយបោះបង់សាកសពដែលគ្មានអត្តសញ្ញាណច្បាស់លាស់នៅជាន់ខាងលើទ្វារ។ ហេតុដូច្នេះបានជាគ្រប់គ្នាខ្ពើមឆ្អើមលែងទៅក្បែរទ្វារនោះបន្ទាប់ពីព្រះអាទិត្យលិចបាត់។

ជំនួសមនុស្សទាំងនោះ សត្វក្អែកជាច្រើនបានហើរជាហ្វូងៗមកផ្តុំគ្នានៅលើទ្វារ។ បើនៅពេលថ្ងៃគេអាចមើលឃើញពួកវាជាច្រើនតែងតែស្រែក ហើយហើរព័ទ្ធជុំវិញលំអរាងកន្ទុយត្រីដែលនៅលើដំបូលទ្វារបាន។ ជាពិសេស ពេលព្រះអាទិត្យរៀបលិច ផ្ទៃមេឃនៅលើដំបូលទ្វារនោះក៏បានឡើងក្រហម ឯសត្វក្អែកក៏លេចធ្លោប៉ះនឹងផ្ទៃមេឃ មើលទៅដូចជាគេបាចគ្រាប់ល្ងត្រង់នេះបន្តិចត្រង់នោះបន្តិច។ ពួកវាហើរមកចឹកស៊ីសាច់របស់សាកសពដែលនៅលើទ្វារនោះ...តែថ្ងៃនេះ ដោយសារពេលយឺតម៉ោងបន្តិចក៏មិនដឹង យើងមើលមិនឃើញសត្វក្អែកទាំងនោះទេ។ ប៉ុន្តែឃើញតែអាចម៍ពណ៌សរបស់វានៅលើកាំជណ្តើរថ្មនៃទ្វារដែល

---

[1] ក្រោមទ្វារដ៏ធំស្ថិតនៅខាងត្បូងទីក្រុងបុរាណ

[2] ផ្លូវដ៏ធំហើយសំខាន់ដែលកាត់ទីក្រុងបុរាណនោះពីជើងទៅត្បូង

[3] មួកសម្រាប់មនុស្សស្រី ប៉ុន្តែទីនេះបង្ហាញន័យថា មនុស្សស្រីដែលលក់ឥវ៉ាន់

[4] មួកសម្រាប់មនុស្សប្រុស ប៉ុន្តែទីនេះបង្ហាញន័យថា មនុស្សសាមញ្ញ

[5] ទីក្រុងបុរាណជប៉ុន

បែកបាក់ត្រង់នេះបន្តិចត្រង់នោះបន្តិច ហើយមានដុះស្មៅវែងៗតាមប្រឡោះថ្មប្រេះនោះ។ បុរសដែលពាក់អាវផាយខៀវសាកពណ៌ បានអង្គុយនៅលើកាំជណ្តើរថ្មទីប្រាំពីរដែលជាកាំខ្ពស់ជាងគេ ហើយកំពុងព្រួយបារម្ភពីមុនដ៏ធំកើតលើថ្ពាល់ស្តាំរបស់គាត់បណ្តើរ និងសម្លឹងមើលដំណក់ទឹកភ្លៀងបណ្តើរ។

ខ្ញុំបានសរសេរពីដំបូងថា "អ្នកបម្រើឋានៈទាបម្នាក់ កំពុងរង់ចាំភ្លៀងរាំង" ប៉ុន្តែតាមពិត បុរសនេះគ្មានគំនិតធ្វើអ្វីទេ បើទោះបីភ្លៀងរាំងក៏ដោយ។ បើតាមធម្មតា គាត់គួរតែត្រឡប់ទៅផ្ទះម្ចាស់របស់គាត់វិញ ប៉ុន្តែគាត់ត្រូវម្ចាស់ដេញចេញប៉ុន្មានថ្ងៃកន្លងមកនេះ។ ដូចបានរៀបរាប់មកខាងលើហើយថា ទីក្រុងក្យូតុនៅពេលនោះជាទីក្រុងដែលស្ថិតក្នុងភាពឱនថយមិនធម្មតា ឥឡូវនេះដោយសារតែផលប៉ះពាល់តូចតាចនេះទើបធ្វើឱ្យម្ចាស់របស់គាត់បណ្តេញចេញ ទោះគាត់ធ្លាប់បានបម្រើ អស់ពេលជាយូរឆ្នាំហើយក្តី។ ដូច្នេះខ្ញុំគួរតែសរសេរថា "បុរសអ្នកបម្រើឋានៈទាបម្នាក់ គ្មានកន្លែងត្រូវទៅទេ ហើយក៏គ្មានគំនិតធ្វើអ្វីផងដែរ" វាប្រសើរជាងខ្ញុំសរសេរថា "បុរសអ្នកបម្រើឋានៈទាបម្នាក់កំពុងរង់ចាំភ្លៀងរាំង" ។ ម៉្យាងទៀត អាកាសធាតុថ្ងៃនេះក៏ជះឥទ្ធិពលទៅដល់ *Sentimentalisme* របស់បុរសនៅសម័យ ហេអ៊ីអាន[6] នោះដែរ។ ភ្លៀងបានបង្អុរ ចាប់តាំងពីពេលល្ងាចបន្តិច ហើយមិនបង្ហាញសញ្ញាថារាំងឡើយ។ បុរសនេះ គាត់បានប្តេជ្ញាចិត្តស្វែងរកមធ្យោបាយចិញ្ចឹមជីវិតទៅថ្ងៃក្រោយ...ពោលគឺថាគិតស្វែងរកមធ្យោបាយដើម្បីដោះស្រាយស្ថានភាពដែលមិនអាចដោះស្រាយបាន ព្រមទាំងស្តាប់សំឡេងទឹកភ្លៀងដែលធ្លាក់នៅលើវិថីស៊ុស្សាក់គុអូយី ពីមុនបន្តិចមក។

ភ្លៀងនាំមកនូវស្នូរសំឡេងយ៉ាងខ្លាំងពីចម្ងាយ ខណៈដែលវាធ្លាក់មកគ្របដណ្តប់លើទ្វាររ៉ាស្ហូម៉ុន។ ភាពងងឹតពេលល្ងាច ធ្វើឱ្យមេឃកាន់តែទាបទៅ រហូតដល់ដំបូលទ្វារ និងជួយឱ្យមានពពកក្រាស់ងងឹត នៅលើកំពូលដំបូលដែលលយចេញកោងទៅលើ។

ដើម្បីធ្វើអ្វីមួយ នៅពេលគ្មានការងារធ្វើ គាត់បានរៀបចំខ្លួនជាស្រេចទោះបីការងារអ្វី ក៏ធ្វើដែរ ហើយប្រសិនបើគាត់រារែក នោះគាត់មុខជានឹងដាច់ពោះស្លាប់ នៅលើដីកន្លែងណាមួយ ឬនៅលើដីបណ្តាយផ្លូវមិនខាន នៅពេលនោះ គេនឹងយកសពគាត់មកទ្វារដ៏ធំនេះ ហើយបោះចោលនៅជាន់លើដូចជាសត្វឆ្កែ។ ប្រសិនបើគាត់បានត្រៀមខ្លួនធ្វើអ្វីក៏បាន...ពោលគឺគំនិតគាត់ដើរលើផ្លូវដដែលម្តងហើយម្តងទៀតនោះប្រាកដជាទៅដល់គោលដៅដដែលមិនខានដែរ។ ប៉ុន្តែមិនខ្វល់ថាចំណាយពេលវេលាច្រើនប៉ុណ្ណាទេ ពាក្យ ‹ប្រសិនបើ› នៅតែ ‹ប្រសិនបើ› ដដែល។ ទោះបីក្នុងខណៈដែលគាត់បានប្រាប់ខ្លួនឯងថា គាត់បានរៀបចំខ្លួនធ្វើអ្វីក៏បានក៏ដោយ គាត់មិនអាចស្វែងរកសេចក្តីក្លាហានសម្រាប់ការដោះស្រាយពាក្យថា ‹ ប្រសិនបើ › នោះបានទេ ពោលគឺ *គ្រប់យ៉ាងដែលគាត់អាចធ្វើបាន គឺធ្វើជាចោរ* ។

គាត់បានកណ្តាស់យ៉ាងខ្លាំង ហើយក្រោកឈរឡើងយ៉ាងខ្ជិល។ ភាពត្រជាក់ពេលល្ងាចនៅក្យូតុខ្លាំងគួរសម ធ្វើឱ្យបុរសនោះចង់បានចង្ក្រានដុតធ្យូងមួយដែលពេញទៅដោយរងើកភ្លើង។ ខ្យល់កាន់តែបក់

[6] សម័យបុរាណជប៉ុនកាលពីគ.ស ៧៩៤ - គ.ស ១១៩២

គ្មានត្រាប្រណីតាមចន្លោះសសរទ្វារជាមួយនឹងភាពងងឹត។ ឥឡូវសូម្បីតែសត្វចង្រិតមួយក៏ត្រូវខ្យល់បក់យកទៅបាត់ពីកន្លែងដែលវាតោងលើសសរមូលក្រហមនោះដែរ។

បុរសដែលពាក់អាវផាយពណ៌ខៀវ និងអាវយឺតក្នុងពណ៌លឿងនោះរួញកហើយចំកោងស្មារបស់គាត់ងាកមើលជុំវិញទ្វារនោះ។ ពីព្រោះគាត់បានគិតក្នុងចិត្តថា " *ប្រសិន បើមានកន្លែងមួយដែលគ្មានខ្យល់ គ្មានភ្លៀង គ្មានភាពភ័យខ្លាចថានរណាមើល ហើយជាកន្លែងដែលអាចគេងលក់ស្រួល គាត់នឹងនៅទីនោះរហូតទល់ភ្លឺ* "។ រំពេចនោះដោយ សំណាងល្អ គាត់ក្រឡេកឃើញជណ្ដើរធំមួយ ពោលគឺជណ្ដើរដែលលាបថ្នាំពណ៌ក្រហម ដែលអាចឡើងទៅជាន់ខាងលើទ្វារបាន។ គាត់គិតថា *នរណាក៏ដោយ ឱ្យតែនៅលើនេះគឺជាសាកសពទាំងអស់* ហើយគាត់ក៏ប្រុងប្រយ័ត្នកុំឲ្យដាវដែលមានដងឈើ របូតចេញពីស្រោម បន្ទាប់មកគាត់ក៏ដាក់ជើងដែលមានស្បែកជើងធ្វើពីចំបើងនោះទៅលើកាំជណ្ដើរក្រោមបំផុត។

ពីរបីនាទីក្រោយមក បុរសម្នាក់ឡើងដល់ពាក់កណ្ដាលជណ្ដើរធំ ដែលចេញទៅដល់ ជាន់លើទ្វាររ៉ាស្សូម៉ុន គាត់ក៏ក្រាបចុះដូចជាសត្វឆ្មា រួចទប់ដង្ហើមលួចមើលទៅខាងលើ។ មានពន្លឺភ្លើងក្រហមព្រិលៗមិនសូវច្បាស់ចាំងមកលើថ្ពាល់ស្ដាំរបស់បុរសនោះ ពោលគឺថ្ពាល់ដែលឈឺចាប់ដោយមុនក្រហម ខ្ទុះនៅក្នុងពុកចង្កាខ្លីៗរបស់គាត់។ មុនដំបូង អ្នកបម្រើនោះគិតថា គ្មាននរណានៅទីនេះក្រៅពីសាកសពដែលនៅខាងលើឡើយ។ ប៉ុន្តែពេលឡើងពីរបីកាំបន្តទៀត គាត់ក៏យល់ច្បាស់ថា មានមនុស្សដុតភ្លើង ហើយដើរចុះឡើងពីកន្លែងមួយទៅកន្លែងមួយ។ គាត់បានឃើញពន្លឺភ្លើងពណ៌ក្រហមព្រិលៗ មិនសូវច្បាស់ភ្លឹបភ្លែតៗនៅលើពិតាន ដែលមានសំបុកពីងពាងព័ទ្ធគ្រប់ជ្រុង។ ដូចនេះ ទោះជាយ៉ាងណាក៏ដោយ មានតែមនុស្សមិនធម្មតាប៉ុណ្ណោះដែលអាចដុតភ្លើងនៅទ្វាររ៉ាស្សូម៉ុននេះ ក្រោមមេឃភ្លៀងហើយងងឹត។

អ្នកបម្រើក៏បានឡើងលបៗដោយធ្វើចលនាយឺតៗតាមសត្វជីងចក់ទៅលើកំពូលនៃជណ្ដើរដ៏ធំនោះ។ គាត់បានខំសម្លឹងមើលទៅក្នុងរូងនៃដំបូលជាន់ទី១ទាំងភ័យខ្លាច ដោយចំកោងខ្លួននិងអើតកតាមដែលអាចធ្វើបាន។

នៅទីនោះគាត់បានឃើញសាកសពដែលមិនស្គាល់អត្តសញ្ញាណមួយចំនួន ដូចពាក្យចចាមអារ៉ាមថាមែន ប៉ុន្តែគាត់មិនអាចប្រាប់បានទេថាមានប៉ុន្មាននាក់ ពីព្រោះពន្លឺភ្លើងម្ដុំនោះ នៅឆ្ងាយហើយតូច អ្វីដែលគាត់អាចមើលឃើញតាមពន្លឺភ្លើងក្រហមព្រិលៗនោះគឺសាកសពខ្លះស្ថិតក្នុងភាពអាក្រាត ខ្លះមានសម្លៀកបំពាក់ ។ សាកសពមនុស្សស្រីនិងមនុស្សប្រុស ហាក់ដូចជាមានភាពច្របូកច្របល់លើគ្នា។ វាពិបាកនឹងជឿថា ពួកគេទាំងអស់មានសភាពជាមនុស្សមានជីវិតនោះឡើយ ព្រោះមើលទៅពួកគេដូចជារូបតុក្កតាដែលធ្វើពីដីដេកសណ្ដូកសន្ធឹងដៃនិងចំហមាត់មិនមានសំឡេងអ្វីសោះ ។ ពន្លឺភ្លើងក្រហមព្រិលៗ អាចឱ្យយើងមើលឃើញស្មា ទ្រូង និងផ្នែកដែលផុសចេញ ហើយផ្នែកខាងក្រោមនៃរាងកាយគ្រាន់តែឃើញជាស្រមោលប៉ុណ្ណោះ។

ក្លិនស្អុយរលួយរបស់សាកសពបានជះមកលើគាត់ ហើយគាត់ក៏បានយកដៃក្តោបច្រមុះ ប៉ុន្តែមួយសន្ទុះក្រោយមក ដៃរបស់គាត់ហាក់ដូចជាភ្លេចក្តោបនិងលែងធុំក្លិនស្អុយ ក្នុងខណៈដែលគាត់បានចាប់អារម្មណ៍ទៅលើអ្វីមួយ។

នៅពេលនេះភ្នែករបស់បុរសនោះបានសម្លឹងឃើញមនុស្សមានជីវិតក្រាបក្នុងចំណោមសាកសព ដោយស្លៀកពាក់រ៉ូបបុរាណពណ៌ក្រហមក្រមៅ នោះគឺស្ត្រីចំណាស់ម្នាក់ដែលទាប ស្គមគ្មានសាច់គ្មានឈាម សក់ស មើលទៅដូចជាសត្វស្វា។ ស្ត្រីចំណាស់នោះកាន់ចន្លុះភ្លើង នៅដៃខាងស្តាំហើយកំពុងសម្លឹងមុខ និងពិនិត្យលើសក់ដ៏វែងរបស់សពមួយ ហើយសពនោះប្រហែលជាមនុស្សស្រី។

ដោយការភ័យខ្លាចមានហុកសិបភាគរយ និងការចង់ដឹងចង់ឃើញមានតែសែសិបភាគរយ ធ្វើឱ្យបុរសនោះភ្លេចដកដង្ហើមមួយស្របក់។ ឃ្លានេះបើខ្ចីពាក្យពីអ្នកនិពន្ធសម័យបុរាណ បង្ហាញពីអារម្មណ៍របស់អ្នកបម្រើថា " សក់ក្បាលនិងរោមលើខ្លួនរបស់គាត់ក៏បះព្រោងឡើង" ។ បន្ទាប់មក ស្ត្រីចំណាស់នោះ ដោតចន្លុះរបស់គាត់ចន្លោះក្តារក្រាល ហើយយកដៃទាំងពីរដាក់លើក្បាលសាកសពដែលគាត់បានពិនិត្យ ហាក់ដូចជាស្វាកំពុងរកចៃឱ្យកូនរបស់វា។ គាត់ចាប់ផ្តើមដកសក់ដ៏វែងរបស់សាកសពមួយសរសៃម្តងៗហើយសក់នោះហាក់ដូចជារបូតចេញពីស្បែកក្បាលយ៉ាងងាយ រាល់ពេលដកម្តងៗ។

គ្រប់ពេលដែលស្ត្រីបានដកសក់នោះ ការភ័យខ្លាចតិចតួចរបស់អ្នកបម្រើបានថយចុះ ហើយជំនួសមកវិញដោយការស្អប់ខ្ពើមយ៉ាងខ្លាំងចំពោះស្ត្រីចំណាស់វិញ។ ...ទេ, នេះអាចធ្វើ ឱ្យយល់ខុស៖ គាត់មិនមានអារម្មណ៍ស្អប់ខ្ពើមស្ត្រីនោះខ្លាំង ដូចការស្អប់ចំពោះវត្ថុអាក្រក់គ្រប់យ៉ាងនោះទេ ពោលគឺអារម្មណ៍ដែលធ្វើឱ្យកម្លាំងរឹងមាំគ្រប់នាទីកន្លងហួស។ ឥឡូវនេះប្រសិន បើមាននរណាម្នាក់តំណាងឱ្យបុរសនោះ ក្នុងការជ្រើសរើស គាត់នឹងរិះគិតនៅក្រោមទ្វារម្តងទៀតវិញថាតើស្លាប់ដោយសារអត់អាហារ ឬក្លាយទៅជាចោរ ហើយប្រហែលជាគាត់ជ្រើសរើសយកការស្លាប់ដោយអត់អាហារ ដោយមិនរារែកឡើយ ដូច្នេះការស្អប់អំពើអាក្រក់កាន់តែធ្វើឱ្យគាត់ឆេះឆួលឡើងៗ ដូចចន្លុះភ្លើងដែលស្ត្រីចំណាស់ បានបញ្ឈរចន្លោះក្តារក្រាលអ៊ីចឹង។

អ្នកបម្រើមិនបានដឹងថា ហេតុអ្វីស្ត្រីចំណាស់កំពុងដកសក់របស់សាកសពទេ ហេតុដូច្នេះហើយមិនអាចនិយាយថាជាអំពើល្អ ឬអំពើអាក្រក់បានឡើយ ប៉ុន្តែចំពោះគាត់ ការដកសក់យ៉ាងសកម្មពីសាកសពពេលយប់មានភ្លៀងនៅរ៉ាស្វូម៉ុនបែបនេះ គឺមិនអាចអត់ទោសឱ្យបានទេ ហើយដែលពេលមុននេះបន្តិច គាត់ខ្លួនឯងបានរៀបគម្រោងដើម្បីក្លាយខ្លួនជាចោរ។

បន្ទាប់មក អ្នកបម្រើក៏ស្ទុះយ៉ាងខ្លាំង ផ្លោះកាំជណ្តើរ ហើយឆក់យកដាវរបស់គាត់ ដែលគ្មានដងបោះជំហានវែងៗទាំងបង្ខំ ឆ្ពោះទៅកន្លែងដែលស្ត្រីនោះក្រាប។ ដោយខ្លាចបុរសនោះឃើញស្ត្រីចំណាស់បានលោតចេញដូចគេបាញ់ចំពាមកៅស៊ូ។

" អ្នកឯងគិតចង់ទៅណា?" អ្នកបម្រើបានគំហកដោយឃាត់ដំណើរស្ត្រីចំណាស់នោះ។ ក្នុងការរត់គេចដោយស្លន់ពេក ធ្វើឱ្យគាត់បានជំពប់ជើងដួលលើសាកសព។ ស្ត្រីចំណាស់ពុះពាររត់គេចពីអ្នកបម្រើ

ប៉ុន្តែត្រូវបានអ្នកបម្រើប្រានខ្ទងគាត់ដួល រំពេចនោះ ការវាយតប់រវាង អ្នកទាំងពីរបានកើតឡើងក្នុងសភាពស្ងប់ស្ងាត់ក្នុងចំណោមសាកសព ប៉ុន្តែលទ្ធផលនៃការពុះពារគឺគ្មានអ្វីគួរឱ្យឆ្ងល់ទេ អ្នកបម្រើបានចាប់ដៃរបស់ស្ត្រីចំណាស់ ពោលគឺស្បែកស្តើងនិងឆ្អឹងដូចជើងមាន់ ហើយចុងបញ្ចប់អ្នកបម្រើបានផ្តួលស្ត្រីចំណាស់ទៅលើក្តារក្រាល។

"អ្នកឯងធ្វើអ្វីកន្លែងហ្នឹង? ប្រាប់ខ្ញុំឥឡូវនេះ បើមិនអីចឹង ខ្ញុំនឹងឱ្យស្គាល់អាមួយនេះ"។

អ្នកបម្រើរុញស្ត្រីចំណាស់ចេញ ក្រោយមកស្រាប់តែដកដាវរបស់គាត់ចេញពីស្រោម ហើយលយដែកពណ៌សទៅមុខភ្នែកស្ត្រីចំណាស់។ ប៉ុន្តែស្ត្រីចំណាស់មិននិយាយអ្វីទាំងអស់។ ដៃទាំងពីររបស់គាត់ញ័រដង្ហក់ជាមួយស្មាទាំងសងខាងឡើងចុះៗ ភ្នែកធំៗទាំងពីរស្ទើរតែជ្រុះគ្រាប់ភ្នែក គាត់ទប់ភាពមានះរបស់គាត់ឲ្យនៅស្ងៀមដូចមនុស្សមិនអាចនិយាយបាន។ ឃើញបែបនេះ អ្នកបម្រើគិតថា ជីវិតរបស់ស្ត្រីចំណាស់នេះរស់ ឬស្លាប់គឺស្ថិតក្នុងកណ្តាប់ដៃរបស់ខ្លួនហើយ។ ហើយមិនដឹងពីអង្កាល់ ស្រាប់តែការយល់ឃើញថ្មីបានរំងាប់នូវកំហឹងដែលឆេះពោលពេញដើមទ្រូងរបស់គាត់ភ្លាម។ ពេលនេះអ្នកបម្រើមានអារម្មណ៍ថា គាត់មានអំនួត និងការពេញចិត្តយ៉ាងខ្លាំងចំពោះអំពើដែលគាត់បានធ្វើ។ អ្នកបម្រើក៏មើលចុះទៅស្ត្រីចំណាស់ ហើយនិយាយដោយសំឡេងសុភាពរាបសាថា

"ខ្ញុំមិនមែនជាមន្ត្រី កេប៊ីអ៊ីស៊ី[7] ទេ ខ្ញុំគ្រាន់តែជាអ្នកដំណើរដែលដើរឆ្លងកាត់ក្រោមទ្វារនេះដោយចៃដន្យ។ ដូច្នេះខ្ញុំមិនចង់ចាប់ចងអ្នកយកទៅណាទេ។ ខ្ញុំគ្រាន់តែចង់ឲ្យអ្នកប្រាប់ខ្ញុំថាតើអ្នកកំពុងធ្វើអ្វីនៅទីនេះ នៅពេលនេះ។"

ស្ត្រីចំណាស់បើកភ្នែកដ៏ធំរបស់គាត់កាន់តែធំឡើងៗ ហើយសម្លក់មុខរបស់អ្នកបម្រើយ៉ាងខ្លាំង។ ភ្នែកក្រហមរបស់គាត់មុតដូចសត្វស្លាបស៊ីសាច់ជាអាហារ។ បន្ទាប់មក មាត់គាត់ហាក់ដូចជា កំពុងទំពារអ្វីមួយ គាត់ចាប់ផ្តើមធ្វើចលនាបបូរមាត់ មើលទៅសឹងតែប៉ះនឹងច្រមុះដោយស្នាមជ្រួញយ៉ាងជ្រៅរបស់គាត់។ អ្នកបម្រើអាចមើលឃើញការធ្វើចលនានៃគ្រាប់ពោននៅលើកដ៏សំគមរបស់គាត់ហើយសំឡេងដង្ហក់ដែលឮចេញពីបំពង់កគាត់ បានរសាត់ចូលក្នុងត្រចៀករបស់អ្នកបម្រើ ឮដូចជាសម្រែកសត្វក្អែក។

"ខ្ញុំដកសក់...ខ្ញុំគិតចង់ដកសក់ដើម្បីធ្វើសក់ពាក់"។

អ្នកបម្រើខកចិត្តដោយបានឮចម្លើយរបស់ស្ត្រីចំណាស់ ជាចម្លើយសាមញ្ញដែលមិនដូចការស្មានសោះ។ ហើយជាមួយការខកចិត្តនេះ ក៏លេចចេញម្តងទៀតនូវការស្អប់ខ្ពើមដែលគាត់មានពីមុនបន្តិចនោះ និងការមើលងាយគ្មានមេត្តាឡើង។ ស្ត្រីចំណាស់ហាក់ដូចជាដឹងនូវអ្វីដែលអ្នកបម្រើកំពុងមានអារម្មណ៍។ ពេលនោះស្ត្រីចំណាស់កាន់ក្នុងដៃម្ខាងនូវសក់វែងដែលគាត់បានដកយកពីក្បាលសាកសពហើយនិយាយជាប់ៗដូចគីង្គក់ថា:

"ប្រាកដហើយការដកសក់ពីក្បាលសាកសព ប្រហែលជាអំពើអាក្រក់ក៏មិនដឹង។ ប៉ុន្តែសាកសពទាំងនេះសមនឹងទទួលបែបនេះ។ ស្ត្រីដែលខ្ញុំបានដក់សក់នេះ គឺនាងធ្លាប់កាត់ពស់ជាច្រើនជាកង់ៗប្រហែល១២ស.ម ហើយហាលថ្ងៃឲ្យស្ងួត បន្ទាប់មកគេលក់សាច់ពស់នោះដូចជាត្រីងៀត នៅកន្លែងការពារ

[7] មន្ត្រីក្រសួងសមត្ថកិច្ច ពោលគឺប៉ូលីសទីក្រុងបុរាណជប៉ុន

រាជវាំងនៅពេលនាងនៅរស់។ ប្រសិនបើនាងមិនស្លាប់ដោយជំងឺឆ្លងរាលដាលទេ ប្រហែលនាង នៅតែលក់បែបនេះដដែលមិនខាន។ ពីព្រោះអ្នកយាមរាជវាំងជាច្រើនបានចូលចិត្តត្រីងៀតរបស់នាង ហើយពួកគទិញសាច់នោះសម្រាប់ជាអាហាររៀងរាល់ថ្ងៃ។ ខ្ញុំមិនបានគិតថានាងធ្វើនេះខុសទេ។ បើនាងមិនធ្វើ មុខជាស្លាប់ដោយអត់អាហារមិនខាន ដូចនេះនាងមិនអាចមិនធ្វើអ៊ីចឹងបានទេ។ ហេតុនេះហើយ ខ្ញុំក៏មិនគិតថាខ្ញុំធ្វើនេះខុសដែរ គឺវាដូចតែគ្នាទេ។ ប្រសិនបើខ្ញុំមិនធ្វើបែបនេះ ខ្ញុំក៏នឹងដាច់ពោះស្លាប់ដែរ។ ដូច្នេះហើយខ្ញុំមិនដឹងធ្វើម៉េចក្រៅពីធ្វើអ៊ីចឹងទេ។ ស្ត្រីនេះយល់ដឹងច្បាស់ថា គេត្រូវធ្វើបែបនេះ ដើម្បីរស់នៅតទៅទៀត ដូច្នេះនាងប្រហែលជាលើកលែងទោសឲ្យខ្ញុំ។"

អ្នកបម្រើបានដាក់ដាវចូលទៅក្នុងស្រោមវិញ ហើយទម្លាក់ដៃឆ្វេងនៅលើដង រួចស្តាប់យ៉ាងជក់ចិត្តពីរឿងស្ត្រីចំណាស់នោះ។ ប្រាកដហើយនៅគ្រានោះដែរដៃស្តាំគាត់បានអង្អែលមុនដែលឡើងខ្ទុះនៅលើថ្ពាល់របស់គាត់។ ខណៈដែលគាត់បានស្តាប់ទឹកចិត្តក្លាហានមួយបានចាប់ផ្តើមកកើតឡើងនៅក្នុងចិត្តរបស់គាត់ ពោលគឺទឹកចិត្តក្លាហានដែលគាត់បានខ្វះពីដំបូងនៅក្រោមទ្វារ ហើយនោះគឺ ទឹកចិត្តក្លាហានមួយដែលកំពុងតែធ្វើចលនាបញ្ច្រាសទិសពីសេចក្តីក្លាហានដែលបានបង្ខំគាត់ទៅចាប់ស្ត្រីចំណាស់នេះ។ ឥឡូវនេះអ្នកបម្រើ មិនរារែករវាងការដាច់ពោះស្លាប់ និងការក្លាយខ្លួនជាចោរឡើយ។ ម៉្យាងទៀត ក្នុងភាវៈផ្លូវចិត្តថ្មីរបស់គាត់ ការដាច់ពោះស្លាប់ ក៏គាត់ស្ទើរតែបំភ្លេចចោលបាត់ពីសតិស្មារតីទៅហើយ នោះគឺវាប្រែប្រួលស្ទើរតែមិនអាចគិតដល់ចំពោះគាត់។

" អ្នកឯងគិតច្បាស់ហើយ មែនទេ?" ពេលស្ត្រីចំណាស់និយាយរួចហើយ អ្នកបម្រើបានបញ្ជាក់ដោយសំឡេងចំអក។ បន្ទាប់មក បោះជំហានទៅកាន់ស្ត្រីចំណាស់ ភ្លាមនោះគាត់បានដកដៃស្តាំ របស់គាត់ចេញពីមុន រួចចាប់កញ្ចឹងកស្ត្រីចំណាស់។ ក្នុងខណៈដែលអ្នកបម្រើចាប់ស្ត្រីចំណាស់ ពាក្យពេចន៍របស់គាត់នាំមកនូវភាពស្រើបស្រាលចំពោះស្ត្រីចំណាស់ ៖

«បើអ៊ីចឹងអ្នកឯងនឹងមិនបន្ទោសខ្ញុំទេ នៅពេលខ្ញុំស្រាតសម្លៀកបំពាក់អ្នកឯង។ ហ្នឹងហើយ គឺអ្វីដែលខ្ញុំត្រូវធ្វើដើម្បីកុំឲ្យដាច់ពោះស្លាប់។»

អ្នកបម្រើបានចាប់ទាញរ៉ូបរបស់ស្ត្រីចំណាស់ចេញ ហើយនៅពេលស្ត្រីចំណាស់បាន ព្យាយាមចាប់កជើងអ្នកបម្រើនោះ ធ្វើឲ្យបុរសនេះធាក់គាត់មួយជើងខ្ទាតទៅលើសាកសព។ បុរសអ្នកបម្រើបានរត់ប្រាំជំហានយ៉ាងលឿនទៅកាន់ជណ្តើរខាងលើបង្អស់ដោយក្រសោប យករ៉ូបរបស់ស្ត្រីចំណាស់នៅនឹងដៃ។ អ្នកបម្រើបានរត់ចុះទៅក្រោមតាមជណ្តើរធំចោត រួចចូលទៅក្នុងយប់ងងឹតបាត់ទៅ។

នៅពេលមិនសូវយូរប៉ុន្មានកន្លងមកទេ ស្ត្រីចំណាស់បានងើបទាំងកាយអាក្រាត ពីចំណោមសាកសព។ ការរអ៊ូរទាំម្នាក់ឯងនិងការថ្ងូរដោយការឈឺចាប់ ស្ត្រីចំណាស់ក៏បានលូនទៅកាន់ជណ្តើរខាងលើបង្អស់ជាមួយនឹងចន្លុះដែលនៅមានភ្លើង។ ស្ត្រីចំណាស់ខំសម្លឹងមើលចុះមកក្រោមទ្វារ ទាំងសក់សខ្ចីរបស់គាត់បានធ្លាក់គ្របលើមុខ ប៉ុន្តែគាត់បានត្រឹមតែឃើញភាពងងឹតនៃពេលយប់ប៉ុណ្ណោះ។

តើអ្នកបម្រើឋានៈទាបម្នាក់នេះទៅណា ធ្វើអ្វី នោះគ្មាននរណាម្នាក់ដឹងឡើយ៕

(ខែ កញ្ញា ឆ្នាំ ១៩១៥)

# ប្រវត្តិអ្នកនិពន្ធ

អ្នកនិពន្ធ «រឿង រ៉ាស្សូម៉ុន» ឈ្មោះ អាគុតាហ្គាវ៉ា រ្យូណុស៊ុគេ គឺជាអ្នកនិពន្ធជប៉ុនម្នាក់ដែលល្បីល្បាញជាងគេ ក្នុងសង្គមអក្សរសាស្ត្រតាំងពីមុន រហូតមកដល់បច្ចុប្បន្ននេះ។ គាត់កើតនៅឆ្នាំ ១៨៩២ នៅទីក្រុងតូក្យូ។ កាលពីក្មេង គាត់មានសុខភាពមិនល្អទេ ប៉ុន្តែគាត់រៀនពូកែ ហើយចូលចិត្តអានសៀវភៅ។ នៅឆ្នាំ ១៩១៣ គាត់បានចូលរៀននៅសាកលវិទ្យាល័យរាជាធិរាជតូក្យូ ផ្នែកអក្សរសាស្ត្រអង់គ្លេស។ ពេលគាត់នៅរៀនក្នុងសាកលវិទ្យាល័យនោះ គាត់បានបោះពុម្ពផ្សាយទស្សនាវដ្ដីមួយជាមួយលោក គុមេ ម៉ាសាអូ និងលោក គីគុជី កាន់ ។ល។ ទស្សនាវដ្ដីនោះមានឈ្មោះថា ស៊ីនស៊ីចូទីបី[៥] ដែលពួកគាត់ទទួលបន្តពីសិស្សច្បងតាំងពីឆ្នាំ១៩០៧ រហូតមកដល់ពេលនេះ។

នៅឆ្នាំ១៩១៥ គាត់បានសរសេររឿង រ៉ាស្សូម៉ុន ចុះផ្សាយក្នុងទស្សនាវដ្ដីផ្សេងទៀតឈ្មោះថា ទេអ៊ីកុគុបុនហ្គាគុ ប៉ុន្តែពេលនោះគាត់មិនទាន់ទទួលបានការចាប់អារម្មណ៍ពីអ្នកអាននៅឡើយទេ រហូតមកដល់ពេលគាត់សរសេររឿង ហាណា នៅក្នុងទស្សនាវដ្ដី ស៊ីនស៊ីចូ ទីបួន ទើបគាត់មានឈ្មោះល្បី ដោយសារអ្នកនិពន្ធល្បីឈ្មោះម្នាក់ ឈ្មោះ ណាត្សឹមេសូសិគិ បានអានរឿងហាណានោះ ហើយបានសរសើរថា ស្នាដៃនោះពិតជាល្អ។

ក្នុងស្នាដៃរបស់លោក អាគុតាហ្គាវ៉ា ច្រើនតែយកលំនាំតាមរឿងបុរាណ ហើយរឿង រ៉ាស្សូម៉ុន ក៏យកលំនាំតាមរឿងមួយក្នុងសៀវភៅឈ្មោះថា កុនយាគុម៉ុណុហ្គាតារីស្ស៊ូ មកធ្វើជាមូលដ្ឋានដែរ។ ប៉ុន្តែគាត់គ្រាន់តែច្នៃប្រឌិតរឿងប្រវត្តិសាស្ត្រតម្រូវតាមការបកស្រាយបច្ចុប្បន្ន ដោយផ្អែកលើមូលដ្ឋាននោះ ហើយបង្កើតជារឿងថ្មីដោយពណ៌នាពីសេចក្ដីត្រមង់ត្រមោចរបស់មនុស្ស និង អត្តទត្តភាពរបស់មនុស្ស ដូច្នេះហើយរឿងរបស់គាត់មិនមែនមានត្រឹមតែ រឿងប្រវត្តិសាស្ត្រប៉ុណ្ណោះទេ។ គាត់ពូកែខាងអក្សរសាស្ត្រអង់គ្លេស ប៉ុន្តែគាត់អាចប្រើភាសាជប៉ុនបានត្រឹមត្រូវ ហើយអាចប្រើស្ទីលសរសេរបានផ្សេងៗ។ ដំណើរការនិពន្ធរបស់គាត់មានភាពស្មុគស្មាញ ប៉ុន្តែការសរសេរនោះមានបច្ចេកទេសល្អប្រសើរជាងគេ។

គាត់រៀនសិក្សាស្រាវជ្រាវតាមលោក ណាត្សឹមេសូសិគិ និងលោក តាកាហាម៉ាក្យុស៊ី ហើយភាគច្រើនគាត់សរសេររឿងខ្លីៗជាស្នាដៃឯក ប៉ុន្តែនៅឆ្នាំ ១៩២៧ គាត់បានសម្លាប់ខ្លួនឯងដោយញ៉ាំថ្នាំពុលហើយការសម្លាប់ខ្លួននោះ គេមិនដឹងថា មូលហេតុអ្វីទេ។ ពេលនោះគាត់ទើបតែមានអាយុ ៣៥ឆ្នាំតែប៉ុណ្ណោះ។

បន្ទាប់ពីលោក អាគុតាហ្គាវ៉ា ស្លាប់ទៅ មិត្តរបស់គាត់ម្នាក់ឈ្មោះ គីគុជីកាន់ បានបង្កើតពិធីប្រគល់រង្វាន់មួយ ដោយដាក់ឈ្មោះថា អាគុតាហ្គាវ៉ា-ស្សូ។ ឥឡូវនេះ គេគោរពពិធីប្រគល់រង្វាន់នោះ ហើយផ្ដល់អំណាចធំជាងគេក្នុងចំណោមពិធីប្រគល់រង្វាន់ផ្សេងៗទៀតនៅក្នុងសង្គមអក្សរសាស្ត្រជប៉ុន។

---

[៥] ទស្សនាវដ្ដីនេះមានសម័យលើក១៩។ ពេលនោះពួកគាត់បោះពុម្ពទស្សនាវដ្ដី ស៊ីនស៊ីចូ សម័យលើកទីបី។

# មរណភាព និងអត្តទត្ថភាព ក្នុងរឿង រ៉ាស្សូម៉ុន

នៅក្នុងរឿងនេះ មានតួឯកសំខាន់ពីរនាក់ គឺអ្នកបម្រើឋានៈទាបម្នាក់ ដែលត្រូវម្ចាស់ដេញចេញប៉ុន្មានថ្ងៃកន្លងទៅ និងស្ត្រីចំណាស់ម្នាក់ ដែលរកស៊ីចិញ្ចឹមជីវិតដោយធ្វើអំពើខុសសីលធម៌នៅលើទ្វារដ៏ធំឈ្មោះ រ៉ាស្សូម៉ុន។

អ្នកបម្រើនោះគ្មានកន្លែងត្រូវទៅទេ ហើយក៏គ្មានគំនិតធ្វើអ្វីផងដែរ។ គាត់ស្ថិតនៅក្នុងសភាពដ៏ពិបាក ពីព្រោះនៅពេលនោះ មានជម្រើសតែប៉ុណ្ណោះមួយគឺគាត់នឹងដាច់ពោះស្លាប់ពីរគឺធ្វើជាចោរ។ នៅពេលគាត់រារែកមិនទាន់បានសម្រេចចិត្ត គាត់បានប្រទះឃើញស្ត្រីចំណាស់ម្នាក់ដែលកំពុងដកសក់ដ៏វែងរបស់សាកសពនៅលើ ទ្វាររ៉ាស្សូម៉ុន។ មុនដំបូង គាត់ភ័យខ្លាច ប៉ុន្តែការភ័យខ្លាចនោះកាន់តែថយចុះ ហើយជំនួសមកវិញដោយវិញ្ញាណយុត្តិធម៌យ៉ាងខ្លាំងចំពោះអំពើរបស់ស្ត្រីចំណាស់វិញ។ បន្ទាប់មក គាត់ចោទសួរស្ត្រីចំណាស់នោះថា តើឯងកំពុងធ្វើអ្វីនៅទីនោះ?។ អំពើក្លាហានរបស់អ្នកបម្រើនោះបង្ហាញន័យថា គាត់ជាមនុស្សចិត្តល្អដោយធម្មតា។ ប៉ុន្តែពេលក្រោយនិយាយគ្នាបានបន្តិចមក ការដោះសាររបស់ស្ត្រីចំណាស់បានធ្វើឲ្យគាត់សម្រេចចិត្តថាធ្វើជាចោរ។ ពេលនោះហើយ ភាពខ្សោយរបស់មនុស្សលេចចេញនៅមុខអ្នកអាន។ អ្នកបម្រើដែលជាមនុស្សល្អដោយធម្មតានោះ មិនអាចគោរពសីលធម៌តទៅទៀតបានទេ ហើយបានប្រព្រឹត្តអំពើប្រាស់ចាកគំនិតខ្លួនឯងឲ្យធ្លាក់ក្នុងលោកដ៏អាក្រក់វិញ។ ការដោះសាររបស់ស្ត្រីចំណាស់នោះមិនមែនត្រឹមតែបដិសេធការគោរពតម្លៃជីវិតដែលជនជាតិជប៉ុនថែរក្សាក្នុងសង្គមជប៉ុនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងយល់ស្របតាមអត្តទត្ថភាព ក្នុងការបន្តជីវិតរស់នៅទៅមុខទៀត។ ឃ្លាចុងក្រោយថា « តើអ្នកបម្រើឋានៈទាបម្នាក់នេះទៅណា ធ្វើអ្វីនោះគ្មាននរណាម្នាក់ដឹងឡើយ» ឃ្លានេះប្រហែលជាបង្ហាញន័យថា តើអត្តទត្ថភាពរបស់អ្នកបម្រើនេះត្រូវគេអភ័យទោសឬអត់? នោះអ្នកនិពន្ធនេះខ្លួនឯង មិនអាចវិនិច្ឆ័យបានទេក៏មិនដឹង។

អ្នកនិពន្ធឈ្មោះ អាគុតាហ្កាវ៉ា រ្យូណុស៊ុគេ តែងតែសរសេររឿងដែលមានប្រធានរឿងសំខាន់បំផុតជាសេចក្តីស្លាប់ និងអត្តទត្ថភាពរបស់មនុស្ស។ រឿង រ៉ាស្សូម៉ុន ជាស្នាដៃឯកដ៏ល្អប្រសើរ ហើយគួរឲ្យចាប់អារម្មណ៍ ពីព្រោះរឿងនេះ បង្ហាញឲ្យគេដឹងពីចំណង់ចំណូលចិត្តរបស់អ្នកនិពន្ធនេះ៕

បកប្រែពីភាសាជប៉ុនដោយៈ ខេយី ។